**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៣១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៨.៧២៥ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកសំបូរ ខេត្តក្រចេះ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ស ម្រេ ច

**មាត្រា១:-**

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៨.៧២៥ (ប្រាំបីពាន់ប្រាំពីររយម្ភៃប្រាំ) ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងឃុំក្បាលដំរី ឃុំរលួសមានជ័យ និងឃុំស្រែជិះ ស្រុកសំបូរ ខេត្តក្រចេះ ដើម្បីធ្វើការវិនិយោគដាំដំណាំកសិឧស្សាហកម្ម (ដាំអំពៅ) ដូចមានក្នុងផែនទី និងនិយាមកាលេខ ២៥៥៥ កណក្រច ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១១ របស់សាលាខេត្តក្រចេះ ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា២:-**

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល ។

**មាត្រា៣:-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

# ផែនទី ទីតាំងដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន តៃសីញ ក្រចេះ ស៊ុងឡើរ ស្ថិតក្នុងស្រុកសំបូរ ខេត្តក្រចេះ




និយាមកាគោលព្រំដីសម្បទានសេដ្ឋកិច្ច

| N | X | y |
|---|---|---|
| A | 651069 | 1414050 |
| B | 651069 | 1418215 |
| C | 672496 | 1417972 |
| D | 656600 | 1407284 |
| E | 655572 | 1407288 |
| F | 655543 | 1414050 |

និយាមកាគោលព្រំព្រៃរក្សាទុក និង តំបន់កាត់ចេញ

| FID | X | Y |
|---|---|---|
| 0 | 655999 | 1410733 |
| 1 | 659178 | 1410053 |
| 2 | 662176 | 1417679 |
| 3 | 661773 | 1416842 |
| 4 | 661041 | 1416842 |
| 5 | 661369 | 1417913 |
| 6 | 661308 | 1418098 |
| 7 | 651945 | 1418204 |
| 8 | 651954 | 1417585 |
| 9 | 651067 | 1417584 |
| 10 | 667193 | 1417996 |
| 11 | 668407 | 1417995 |
| 12 | 668680 | 1417535 |
| 13 | 668441 | 1416761 |
| 14 | 668336 | 1416487 |
| 15 | 667925 | 1415027 |
| 16 | 667668 | 1416211 |
| 17 | 667690 | 1417330 |
| 18 | 660218 | 1409665 |
| 19 | 660395 | 1409783 |
| 20 | 661132 | 1410364 |

| N | X | Y |
|---|---|---|
| a | 652409 | 1418196 |
| b | 652216 | 1417999 |
| c | 660598 | 1418106 |
| d | 660775 | 1417999 |
| g | 663329 | 1418000 |
| h | 663507 | 1417999 |
| k | 655543 | 1413999 |
| j | 656000 | 1413999 |
| l | 655999 | 1407292 |
| e | 661853 | 1418089 |
| f | 661975 | 1417999 |

**សញ្ញាសម្គាល់**

- • និយាមកាគោលព្រៃរក្សាទុក
- • និយាមកាគោលតំបន់កាត់ចេញ
- ⊙ និយាមកាគោលព្រំ
- ផ្លូវទឹក
- ផ្លូវ
- ព្រំប្រទល់ឃុំ
- ព្រំប្រទល់ដីសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន
- ដីសម្បទានសេដ្ឋកិច្ច

**ផ្ទៃដីត្រូវកាត់ចេញ**

- តំបន់ត្រៀមសម្បទានដីសង្គមកិច្ច(១០ភាគរយ):៩០២ហិកតា
- តំបន់ទ្រនាប់ជងអូរ:១.២៩៤ ហិកតា
- ព្រៃត្រូវរក្សាទុក:៣៤៦ ហិកតា

-ផ្ទៃដីជាន់លើក្រុមហ៊ុន ស៊ីអែនអីហ្គ្រូប: ១៤០ ហិកតា

-ផ្ទៃដីជាន់លើក្រុមហ៊ុន អាហ្គ្រោអ៊ិនដាសស្ទ្រីហ្គ្រូប: ២៩៧ ហិកតា

-ផ្ទៃដីជាន់លើក្រុមហ៊ុន ទ្រូបអែនឡែន: ២៦ ហិកតា

**ផ្ទៃដីត្រូវកាត់ចេញសរុប=៣.០០៥ ហិកតា**

**ផ្ទៃដីមិនកាត់កំឡូមាន**

**១១.៧៣០ ហិកតា - ៣.០០៥ ហិកតា = ៨.៧២៥ ហិកតា**

**ក្នុងនោះ តាមគម្របព្រៃឈើឆ្នាំ២០០៦ មាន**

- ព្រៃពាក់កណ្ដាលស្រោងៈ ៥ ហិកតា
- ព្រៃល្បោះ: ៨.៤១៥ ហិកតា
- ព្រៃគុម្ពោតស្ងួត: ៦ ហិកតា
- ដីគ្មានគម្របព្រៃ: ២៩៩ ហិកតា

**ផ្ទៃដីមិនកាត់កំឡូសរុប = ៨.៧២៥ ហិកតា**

លេខ:.....................

បានឃើញ និង ឯកភាព

សូមគោរពជូន លោកអភិបាលស្រុកមេត្តាពិនិត្យនិងសម្រេច

ថ្ងៃទី 14.12.2011 ថ្ងៃទី 13.12.2011 ថ្ងៃទី 12.12.2011

មេឃុំក្បាលដំរី មេឃុំស្នួលខ្ពស់ មេឃុំស្រែជិះ

លេខ: 388 ......

បានឃើញ និង ឯកភាព

សូមគោរពជូន ឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យនិងសម្រេច

ថ្ងៃទី ...... ខែ ...... ឆ្នាំ 2011

អភិបាលស្រុក

លេខ: ......

បានឃើញ និង ឯកភាព

សូមគោរពជូន ឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យនិងសម្រេច

ថ្ងៃទី 26 ខែ ...... ឆ្នាំ 2011

ប្រធានមន្ទីរកសិកម្មខេត្ត

គឹម ហេត

លេខ: ......

បានឃើញ និង ឯកភាព

សូមគោរពជូន ឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យនិងសម្រេច

ថ្ងៃទី ...... ខែ ...... ឆ្នាំ 2011

ប្រធានមន្ទីរដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដីខេត្ត

ម៉ាន់ សុជាត

លេខ: ......

បានឃើញ និង ឯកភាព

គោរពជូន ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ មេត្តាពិនិត្យ និង សម្រេច

ថ្ងៃទី ...... ខែ ...... ឆ្នាំ ......

អភិបាលខេត្ត

ខាំ ......